ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

MINISTRY OF ECONOMY AND FINANCE

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ១៧១ សហវ.ប្រក

# ប្រកាស

## ស្តីពី

## ការអនុញ្ញាតអោយប្រើប្រាស់ប្រព័ន្ធហិរញ្ញវត្ថុ និង រដ្ឋបាលសំរាប់កម្មវិធីសិលា

## ទេសរដ្ឋមន្ត្រី

## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស /រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រម លេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួង សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

-បានឃើញអនុក្រឹត្យលេខ ៥៧ អនក្រ. បក ចុះថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០០១ ស្តីពីការរៀបចំ និង ប្រព្រឹត្តទៅរបស់គណៈកម្មាធិការដឹកនាំការងារនៃកម្មវិធីសិលា

-យោងប្រកាសលេខ ២៩២ ត.ជ.ន.ស ចុះថ្ងៃទី ០៨ ខែ វិច្ឆិកា ឆ្នាំ២០០២ ស្តីពីការរៀបចំរចនាសម្ព័ន្ធ និង តួនាទីភារៈកិច្ចរបស់គណៈកម្មាធិការអភិវឌ្ឍន៍ជនបទខេត្ត-ក្រុងនៃកម្មវិធីសិលា

-យោងតាមអនុសាសន៍របស់អង្គសិក្ខាសាលាជាតិ ស្តីពីការគ្រប់គ្រងហិរញ្ញវត្ថុ និងរដ្ឋបាលសិលា ដែលបានរៀបចំឡើងនៅថ្ងៃទី ១៣-១៥ ខែ ធ្នូ ឆ្នាំ ២០០៤ នៅក្រុងព្រះសីហនុ

## សំរេច

**ប្រការ ១ :** គណៈកម្មាធិការដឹកនាំការងារនៃកម្មវិធីសិលា និងអភិបាលខេត្ត-ក្រុង ត្រូវអនុវត្តតាមនីតិវិធី និងបទប្បញ្ញត្តិដូចដែលមានចែងនៅក្នុងសៀវភៅណែនាំ ដែលបានជូនភ្ជាប់មកជាមួយនេះ ។

**ប្រការ ២ :** គណៈកម្មាធិការដឹកនាំការងារនៃកម្មវិធីសិលា និងអភិបាលខេត្ត-ក្រុង មានសិទ្ធប្រើប្រាស់គណនីនៅធនាគារ

ពាណិជ្ជកម្ម សំរាប់គ្រប់គ្រងហិរញ្ញប្បទានបរទេស ដែលបានផ្តល់សំរាប់អនុវត្តផែនការវិនិយោគសិលា ។ គណនីធនាគារខាងលើត្រូវបើកក្នុងនាមគណៈកម្មាធិការដឹកនាំការងារនៃកម្មវិធីសិលា ឬ គណៈកម្មាធិការប្រតិបត្តិនៃគណៈកម្មាធិការអភិវឌ្ឍន៍ជនបទ ខេត្ត-ក្រុង ក្រោមការគ្រប់គ្រងរបស់ប្រធានគណៈកម្មាធិការដឹកនាំការងារនៃកម្មវិធីសិលា ឬ អភិបាល ខេត្ត-ក្រុង ។

**ប្រការ ៣ :** អគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារនៃកម្មវិធីសិលា ប្រធានមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុខេត្ត-ក្រុង និងប្រធានរតនាគារខេត្ត-ក្រុង ដែលជាសេនាធិការរបស់គណៈកម្មាធិការដឹកនាំការងារនៃកម្មវិធីសិលា និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុត្រូវជួយណែនាំមុខជំនាញ ដល់គណៈកម្មាធិការប្រតិបត្តិនៃគណៈកម្មាធិការអភិវឌ្ឍន៍ជនបទខេត្ត-ក្រុង ក្នុងការអនុវត្តន៍ ប្រព័ន្ធហិរញ្ញវត្ថុសិលានេះ ។

**ប្រការ ៤ :** អភិបាលខេត្ត-ក្រុងដែលជាប្រធានគណៈកម្មាធិការអភិវឌ្ឍន៍ជនបទខេត្ត-ក្រុងត្រូវតែងតាំងមន្ត្រីសវនកម្មផ្ទៃក្នុង ។ មន្ត្រីសវនកម្មផ្ទៃក្នុងនេះ ត្រូវបំរើការងារជាបុគ្គលិកពេញម៉ោងរបស់គណៈកម្មាធិការប្រតិបត្តិនៃ គណៈកម្មាធិការអភិវឌ្ឍន៍ជនបទខេត្ត-ក្រុង។ មន្ត្រីសវនកម្មផ្ទៃក្នុងត្រូវរាយការណ៍ដោយផ្ទាល់ជូនអភិបាលខេត្ត-ក្រុងអំពីការផ្ទៀងផ្ទាត់ និងត្រួតពិនិត្យការអនុវត្តន៍ប្រព័ន្ធហិរញ្ញវត្ថុសិលារបស់គ្រប់ភ្នាក់ងារសិលាទាំងអស់នៅថ្នាក់ខេត្ត-ក្រុង ។

**ប្រការ ៥ :** ប្រកាសលេខ ០៨៥ សហវ ចុះថ្ងៃទី ០៥ កុម្ភៈឆ្នាំ ២០០៣ ស្តីពីការអនុញ្ញាតអោយប្រើប្រាស់ប្រព័ន្ធហិរញ្ញវត្ថុ និងរដ្ឋបាលសំរាប់កម្មវិធីសិលា ព្រមទាំងបទប្បញ្ញត្តិទាំងឡាយណារបស់គណៈកម្មាធិការដឹកនាំការងារនៃកម្មវិធីសិលាដែលផ្ទុយនឹងប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ ៦ :** ប្រធានគណៈកម្មាធិការដឹកនាំការងារនៃកម្មវិធីសិលា អភិបាលខេត្ត-ក្រុង និងប្រធានមន្ទីរហិរញ្ញវត្ថុខេត្ត-ក្រុងត្រូវទទួលខុសត្រូវអនុវត្តប្រកាសនេះ ។

**ប្រការ ៧ :** ប្រកាសនេះមានប្រសិទ្ធិភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅភ្នំពេញ ថ្ងៃទី ២៧ ខែ ០៧ ឆ្នាំ ២០០៥

គាត ឈន់

ចំលងជូន :

-ខុទ្ទកាល័យព្រះមហាក្សត្រ

-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

-ទីស្តីការគណៈរដ្ឋមន្ត្រី

"ដើម្បីជូនជ្រាប"

-អភិបាលខេត្ត-ក្រុង

-គណៈកម្មាធិការដឹកនាំការងារនៃកម្មវិធីសិលា

"ដើម្បីអនុវត្ត"

-ឯកសារ